**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ព្រហស្បតិ៍ ៩ កើត ខែ ចេត្រ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីដាក់ដំណើរការជាផ្លូវការកម្មវិធីបណ្តុះបណ្តាលស្តីពី "ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា"

នារសៀលថ្ងៃទី **២៩ ខែ មីនា ឆ្នាំ ២០២៣ វេលាម៉ោង ២:០០ រសៀល ដល់ម៉ោង ៥:០០ រសៀល** នៅសណ្ឋាគារ Oakwood Premier Phnom Penh គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងក្រុមហ៊ុន META បានសហការរៀបចំពិធីដាក់ដំណើរការជាផ្លូវការកម្មវិធីបណ្តុះបណ្តាលស្តីពី "**ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា**"។ ពិធីនេះបានប្រព្រឹត្តទៅ ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដោយមានការចូលរួមពីតំណាងសមាគម, ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន សរុបប្រមាណ ១០០ នាក់។

កម្មវិធីបណ្តុះបណ្តាល "**ការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់សហគ្រាសកម្ពុជា**" គឺជាកម្មវិធីបណ្តុះបណ្តាលដែលមានរយៈពេល ៨ សប្តាហ៍ ដែលត្រូវបានសហការរៀបចំឡើងដោយគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងក្រុមហ៊ុន META។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំក្នុងគោលបំណងសំខាន់ៗ ចំនួន ៤៖ (១) បង្កើនការយល់ដឹងទូលំទូលាយពីការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងតួនាទីរបស់វានៅក្នុងបរិយាកាសអាជីវកម្មនាពេលបច្ចុប្បន្ន, (២) បង្កើនជំនាញ និងចំណេះដឹងចាំបាច់ក្នុងការអភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រទីផ្សារប្រកបដោយប្រសិទ្ធភាពខ្ពស់, (៣) យល់ដឹងអំពីរបៀបបង្កើត និងរៀបចំមាតិកាដែលមានគុណភាពខ្ពស់ និងទាក់ទាញ ដែលស្របតាមគោលដៅប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ខ្លួន, និង (៤) យល់ដឹងអំពីរបៀបបង្កើត និងចូលរួមជាមួយសហគមន៍លើប្រព័ន្ធផ្សព្វផ្សាយសង្គម។ វគ្គបណ្តុះបណ្តាលនេះ នឹងរៀបចំឡើងចំនួន **២លើក** ក្នុងឆ្នាំ ២០២៣ ដែលលើកទី១ គឺចាប់ពីថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២៣ និងលើកទី២ គឺចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២៣ ដោយរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ ទៅដល់សហគ្រាសសរុបចំនួន ១០០ ក្នុងការកសាងបណ្តាញទំនាក់ទំនង និងការអភិវឌ្ឍចំណេះដឹង និងជំនាញទីផ្សារឌីជីថលនៅក្នុងសេដ្ឋកិច្ចឌីជីថលកម្ពុជា។

ពិធីដាក់ដំណើរការជាផ្លូវការនេះ ត្រូវបានចាប់ផ្ដើមដំណើរការដោយមតិស្វាគមន៍របស់ **លោកបណ្ឌិត ហេង ភក្តី** អ្នកគ្រប់គ្រងគោលនយោបាយសាធារណៈនៃក្រុមហ៊ុន META និងសុន្ទរកថាបើករបស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។ ក្នុងការថ្លែងសុន្ទរកថាបើកនេះ **ឯកឧត្តមបណ្ឌិត** បានលើកឡើងពីសក្តានុពល និងកាលានុវត្តភាពនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការបង្កើនផលិតភាព និងប្រសិទ្ធ-ភាពនៃការធ្វើប្រតិបត្តិការអាជីវកម្ម និងការពង្រីកទីផ្សារអាជីវកម្មក្នុងវិស័យសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម។

ក្នុងដំណើរការនៃពិធីដាក់ដំណើរការនេះដែរ, វាគ្មិនកិត្តិយស ដែលជាម្ចាស់សហគ្រាស និងអ្នកជំនាញបានចូលរួមចែករំលែកនូវបទពិសោធន៍ជាក់ស្តែងទាក់ទងទៅនឹងការអនុវត្តការស្វែងរកទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ ក៏ដូចជាការលើកឡើងនូវទស្សនៈមួយចំនួនលើសារៈសំខាន់នៃការធ្វើទីផ្សារបែបឌីជីថលសម្រាប់សហគ្រាសក្នុងយុគសម័យឌីជីថល។ ជាមួយគ្នានេះដែរ, ពិធីដាក់ដំណើរការនេះក៏មានការធ្វើបទបង្ហាញអំពីកម្មវិធីបណ្តុះបណ្តាល រួមមានទិដ្ឋភាពទូទៅនៃកម្មវិធី, ម៉ូឌែលវគ្គសិក្សា និងកាលវិភាគសិក្សា, អត្ថប្រយោជន៍, លក្ខន្តិកៈ និងតម្រូវការក្នុងការចូលរួមនៃកម្មវិធី អមជាមួយនឹងការសួរសំណួរជាច្រើនពីអ្នកចូលរួមរបស់យើងផងដែរ។

ជាកិច្ចបញ្ចប់, **ឯកឧត្តមបណ្ឌិត ឈៀប ចណ្ណាមុនិណ្ណា** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល បានអញ្ជើញថ្លែងសុន្ទរកថាបិទដោយគូសរំលេចពីសារៈប្រយោជន៍មួយចំនួនរបស់វគ្គបណ្តុះបណ្តាល ក្នុងការបង្កើនសមត្ថភាព និងចំណេះដឹងផ្នែកការធ្វើទីផ្សារបែបឌីជីថល ដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីដំណើរការអាជីវកម្មប្រកបដោយភាពជោគជ័យ។ **ឯកឧត្តមបណ្ឌិត** ក៏បានលើកទឹកចិត្តសហគ្រាសទាំងអស់ចូលរួម និងផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលនេះ ដើម្បីទទួលបាននូវព័ត៌មាន និងចំណេះដឹងបន្ថែមពីអ្នកជំនាញច្បាស់លាស់ ដើម្បីយកទៅអនុវត្ត និងដំណើរការអាជីវកម្មរបស់ខ្លួនកាន់តែប្រសើរ។

ពិធីដាក់ដំណើរការនេះបានប្រព្រឹត្តទៅយ៉ាងរលូន និងទទួលបានលទ្ធផលគាប់ប្រសើរដូចការរំពឹងទុក ថែមទាំងទទួលបានធាតុចូលល្អៗជាច្រើន តាមរយៈការពិភាក្សា, ការចែករំលែកទស្សនាទាន, គំនិតនវានុវត្តន៍ និងបទពិសោធន៍ជាក់ស្តែងពីវាគ្មិនកិត្តិយស និងអ្នកចូលរួមទាំងអស់។

សូមចូលទៅកាន់ www.digitaleconomy.gov.kh/trainings/digital-marketing ដើម្បីស្វែងយល់បន្ថែមពីវគ្គបណ្តុះបណ្តាលខាងលើ និងធ្វើការចុះឈ្មោះ។ សម្រាប់ការស្រាយចម្ងល់ផ្សេងទៀត សូមផ្ញើសារមកកាន់ទំព័រហ្វេសប៊ុកផ្លូវការ

**១. គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល - គសធឌ**

( www.facebook.com/digitaleconomyandbusinesscommittee )

**២. មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"**

( www.facebook.com/Techo.Startup.Center )។